**AUSTRALIAN EMBASSY**
**PHNOM PENH**

# សេចក្តីប្រកាសព័ត៌មាន

## អូស្ត្រាលីបានបញ្ចប់នូវកិច្ចការសំរាប់ពាណិជ្ជកម្មនៅអាស៊ីអគ្នេយ៍

លោករដ្ឋមន្ត្រីពាណិជ្ជកម្ម Simon Crean បានប្រកាសនាថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ នេះថាប្រទេសអូស្ត្រាលីបានបញ្ចប់រួចរាល់ហើយនូវកិច្ចចរចារស្តីអំពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីថ្នាក់តំបន់ អាស៊ាន អូស្ត្រាលី នូវែហ្សេឡង់ ឬហៅកាត់ថា AANZFTA ។

ប្រទេសអូស្ត្រាលីនឹងទទួលបាននូវផលចំណេញយ៉ាងច្រើនគួរឱ្យកត់សំគាល់ អំពីកិច្ចព្រមព្រៀងនេះនៅក្នុងវិស័យជាច្រើន ។ យើងទទួលបាននូវផលចំណេញផ្នែកទីផ្សារនៅក្នុងវិស័យជាច្រើន រួមទាំងកសិកម្ម និង ផលិតផលឧស្សាហកម្ម ។

យើងបានធានាឱ្យមាននូវលទ្ធផលគួរជាទីពេញចិត្តខាងផ្នែកសេវាកម្ម ដែលនឹងបង្កើតនូវភាពជាក់លាក់បន្ថែមសំរាប់អ្នកនាំចេញនូវវិស័យមួយចំនួនដូចជា វិស្វកម្ម ការអប់រំ និងវិស័យហិរញ្ញវត្ថុ ។ កិច្ចព្រមព្រៀងនេះបានរាប់បញ្ចូលនូវបញ្ញត្តិនានាដែលផ្តល់នូវភាពជាក់លាក់ និងតម្លាភាពច្រើនជាងមុនសំរាប់វិនិយោគិនអូស្ត្រាលី ។ អូស្ត្រាលី បានទទួលនូវការកាត់បន្ថយពន្ធគយយ៉ាងច្រើនគួរឱ្យកត់សំគាល់ ហើយក៏កំពុងធ្វើកិច្ចការជាមួយប្រទេសពីរ ដើម្បីសំរេចឱ្យបាននូវការរីកចំរើនផ្នែកពាណិជ្ជកម្មបន្ថែមទៀត ។

ជាក់ស្តែង យើងកំពុងពង្រឹងសមិទ្ធផលខាងវិស័យយានយន្ត ជាមួយប្រទេសឥណ្ឌូនេស៊ី និង ម៉ាឡេស៊ី ។

សំខាន់ជាងនេះទៅទៀត យើងបានទទួលនូវការប្តេជ្ញាចិត្តពីដៃគូរចរចាររបស់យើង ថានឹងបន្តពង្រីកបន្ថែមលើលទ្ធផលទាំងអស់នេះនាពេលអនាគត ។

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី AANZFTA នឹងទាញយកផលចំណេញចេញពីឱកាសពាណិជ្ជម្ម និងសេដ្ឋកិច្ចនានា ដែលនឹងត្រូវបង្កើតឡើងតាមរយៈការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន ។

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនេះ គឺជាកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលមានលក្ខណៈទូលំទូលាយបំផុតដែលអាស៊ានធ្លាប់បានចរចារបង្កើតឡើង ។ ចំពោះវិសាលភាព កិច្ចព្រមព្រៀងនេះ គឺជាកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលធំជាងគេបំផុត ដែលប្រទេសអូស្ត្រាលីធ្លាប់បានចូលរួមចរចារបង្កើតឡើង ។ កិច្ចព្រមព្រៀងនេះគ្របដណ្តប់លើពាណិជ្ជកម្ម ដែលមានតំលៃ $71ពាន់លាន ឬ 16ភាគរយ នៃពាណិជ្ជកម្មទំនិញ និងសេវាកម្មសរុបរបស់អូស្ត្រាលី ។

នេះគឺជាទីផ្សារដ៏ធំដែលមានប្រជាជនសរុប 570លាន នាក់ និងផលទុនសេដ្ឋកិច្ចក្នុងស្រុកសរុប(GDP) 1ពាន់កោដដុល្លាអាមេរិច ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី AANZFTA នឹងពង្រឹងចំណង ពាណិជ្ជកម្ម និងវិនិយោគជាមួយអាស៊ាន ។

នៅក្នុងកិច្ចព្រមព្រៀងនេះ យើងសង្កេតឃើញមានសក្តានុពលក្នុងការបង្កើតឱកាសពាណិជ្ជកម្ម និងពាណិជ្ជកម្មថ្មីៗ ដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេរភាគីពុំអាចផ្តល់ឱ្យ ។ កិច្ចព្រមព្រៀងថ្ងៃនេះ បានបង្ហាញនូវសញ្ញាណជាវិជ្ជមាននូវថាមភាពសេដ្ឋកិច្ចនៃតំបន់របស់យើង និងផ្តល់ឱ្យនូវប្លុកនៃសមាហរណកម្មថ្នាក់តំបន់មួយ ។

នៅឆ្នាំ 2007 ពាណិជ្ជកម្មទំនិញសរុបទាំងនាំចេញនិងនាំចូល រវាងប្រទេសអូស្ត្រាលី និងកម្ពុជា មានតំលៃសរុប $61លាន ។ សព្វថ្ងៃនេះ មានក្រុមហ៊ុនអូស្ត្រាលីធំៗកំពុងវិនិយោគនៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងវិស័យធនាគារ ធនធានធម្មជាតិ និងការអភិវឌ្ឍន៏អចលនទ្រព្យ ។

ពាណិជ្ជកម្មតំបន់ដែលកាន់តែរីកចំរើន នឹងក្លាយជាគន្លឹះនៃកិច្ចប្រឹងប្រែងរបស់កម្ពុជា និងតំបន់អាស៊ីអគ្នេយ៏ក្នុងការកាត់បន្ថយភាពក្រីក្រ និងការពង្រីកកំណើនសេដ្ឋកិច្ច ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី AANZFTA នេះនឹងដើរតួសំខាន់នៅក្នុងការពន្លឿនកិច្ចប្រឹងប្រែងទាំងនេះ ។

**ទំនាក់ទំនងការផ្សាយៈ លោកស្រី ហ៊ីយុណា ខស្សូ លេខាទី១**

**ទូរស័ព្ទលេខៈ ០២៣ ២១៣ ៤៧០**

**ស្ថានទូតអូស្ត្រាលីនៅភ្នំពេញ**

**ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៨**